សេចក្ដីថ្លែងការណ៍រួម

# ពិព័រណ៍រូបថតរបស់អង្គការសមាគមធាងត្នោត
# មិនគួរត្រូវបានផ្អាក ហើយអាជ្ញាធរគួរទទួលខុសត្រូវ

ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤

យើងខ្ញុំទាំងអស់គ្នាជា អង្គការសង្គមស៊ីវិល និងសហគមន៍មូលដ្ឋាននៅរាជធានីភ្នំពេញ និងខេត្ត ដែលមានរាយឈ្មោះដូចខាងក្រោម មានសេចក្ដីសោកស្ដាយ និងខកចិត្តជាខ្លាំងចំពោះ ដែលអាជ្ញាធរសង្កាត់និរោធ និងខណ្ឌច្បារអំពៅ បានបញ្ជាឱ្យម្ចាស់ទីតាំងបញ្ឈប់ និងរុះរើពិព័រណ៍រូបថតក្រោមប្រធានបទ "ផ្ទះ និងជីវិត" របស់អង្គការសមាគមធាងត្នោត កាលពីថ្ងៃ២៥ ខែកុម្ភៈ ឆ្នាំ២០២៤ នៅភោជនីយដ្ឋានសួនចំប៉ី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញដោយគ្មានមូលហេតុ និងមិនបានជូនដំណឹងជាមុន ។

ពិព័រណ៍រូបថតនេះ ធ្វើឡើងក្នុងគោលបំណងនាំយកពីទុក្ខកង្វល់ និងបញ្ហារបស់សហគមន៍ក្រីក្រនៅរាជធានីភ្នំពេញ ឱ្យភាគីពាក់ព័ន្ធបានដឹង និងចូលរួមគ្នាក្នុងការផ្ដល់នូវដំណោះស្រាយ។

ការបញ្ឈប់ និងរុះរើពិព័រណ៍រូបថតរបស់អង្គការសមាគមធាងត្នោតខាងលើ ដោយមិនបានជូនដំណឹង និងប្រាប់ពីមូលហេតុជាក់លាក់នេះ គឺជាការរំលោភយ៉ាងច្បាស់ មកលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងជាសកម្មភាពដែលមិនផ្ដល់តម្លៃចំពោះសិល្បៈ ។ ពិព័រណ៍រូបថតនេះ គឺជាសិល្បៈដ៏សំខាន់មួយ ដែលបង្ហាញអំពីរឿងរ៉ាវរបស់សហគមន៍ក្រីក្រនៅរាជធានី និងភាពងាយរងគ្រោះរបស់ពួកគេ ។ យើងខ្ញុំនៅតែសោកស្ដាយជាខ្លាំង ចំពោះការបន្តបង្ក្រាប និងបំបិទសិទ្ធិដោយមិនត្រឹមត្រូវបែបនេះ មកលើសកម្មភាព ឬទម្រង់សិល្បៈមួយ ដែលជាសេរីភាពក្នុងការបញ្ចេញមតិ ក្នុងអណត្តិរាជរដ្ឋាភិបាលថ្មីនេះ ។

រដ្ឋធម្មនុញ្ញបានធានានូវ សិទ្ធិ និងសេរីភាពក្នុងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋ និងគោលការណ៍នីតិរដ្ឋ។ ផ្ទុយទៅវិញអាជ្ញាធរមួយចំនួន បែរជាបំបិទសំឡេងរបស់ប្រជាពលរដ្ឋ សង្គមស៊ីវិល ដែលអ្នកទាំងនោះគ្រាន់តែបង្ហាញអំពីការព្រួយបារម្ភ ទៅលើជីវភាពរស់នៅរបស់ពលរដ្ឋក្រីក្រមួយចំនួន ក្នុងរាជធានីភ្នំពេញ។ អាជ្ញាធរគួរតែមកព្យាយាមដោះស្រាយបញ្ហាដែលកើតមានទៅលើពលរដ្ឋទាំងនោះ ដែលរួមមានការរំលោភយកដីធ្លី ការផ្ដល់កម្ចីឥណទានបែបកេងប្រវ័ញ្ច និងការបញ្ចាំខ្លួនដោះបំណុល ជាដើម ដែលតែងតែកើតមានទៅលើពលរដ្ឋក្រីក្រទាំងនោះ។

យើងខ្ញុំជាសមាគម អង្គការសង្គមស៊ីវិល និងពលរដ្ឋសហគមន៍មូលដ្ឋាន ដូចមានរាយនាមខាងក្រោម អំពាវនាវ សូមឱ្យអាជ្ញាធរអនុញ្ញាតឱ្យបន្តពិព័រណ៍រូបថតឡើងវិញដោយគ្មានការរំខាន។ យើងខ្ញុំក៏សំណូមពរដល់ក្រសួងមហាផ្ទៃធ្វើការពិនិត្យពីសកម្មភាពរបស់អាជ្ញាធរខណ្ឌច្បារអំពៅ និងសង្កាត់និរោធ និងសូមឱ្យពួកគេបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់នៃការផ្អាកការតាំងពិព័រណ៍រូបថត។ បន្ថែមពីនេះទៅទៀត យើងខ្ញុំក៏ស្នើសុំឱ្យស្ថាប័នទាំងពីរទទួលខុសត្រូវចំពោះរឿងនេះផងដែរ។ ជាចុងក្រោយ យើងខ្ញុំទាំងអស់គ្នាក៏ស្នើសុំឱ្យក្រសួងមហាផ្ទៃសូមធ្វើការណែនាំដល់អាជ្ញាធរមូលដ្ឋាននៅទីតាំងផ្សេងៗទៀត ដើម្បីធានាធាថាសិទ្ធិសេរី

ភាពជាមូលដ្ឋានរបស់ពលរដ្ឋមិនត្រូវបានអាជ្ញាធររឹតត្បិត ជាពិសេសរឿងដូចគ្នានេះ ឬប្រហាក់ប្រហែលនេះ នឹងមិនមានកើតមាននៅពេលក្រោយទៀតទេ។

**សេចក្តីថ្លែងការណ៍រួមនេះគាំទ្រដោយៈ**

១. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា

២. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

៣. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និង សិទ្ធមនុស្ស

៤. វិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា

៥. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា

៦. សមាគមបណ្តាញយុវជនកម្ពុជា

៧. សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ

៨. សហគមន៍ កៅពីរ

៩. សហគមន៍ ចម្រើន

១០. សហគមន៍ ឆ្មាអើត

១១. សហគមន៍ ដក់ពរ (កំពង់ស្ពឺ)

១២. សហគមន៍ ដីធ្លីស្រែប្រាំង (ត្បូងឃ្មុំ)

១៣. សហគមន៍ ដីធ្លី (ប៉ៃលិន)

១៤. សហគមន៍ ដីធ្លីអណ្តូងត្របែក (ស្វាយរៀង)

១៥. សហគមន៍ ដីធ្លី ១៩៧ (កោះកុង)

១៦. សហគមន៍ ត្រពាំងជោ (កំពង់ស្ពឺ)

១៧. សហគមន៍ ត្រពាំងរាំង

១៨. សហគមន៍ ថ្នាន់មួយរយ

១៩. សហគមន៍ ទ្រទ្រង់ធម្មជាតិ (ពោធិ៍សាត់)

២០. សហគមន៍ ធនធានព្រៃឈើស្នឹងខ្សាច់ស (កំពង់ឆ្នាំង)

២១.  សហគមន៍ ទំនប់តាថ្លាង

២២. សហគមន៍ បឹងឈូកមានជ័យថ្មី២

២៣. សហគមន៍ បឹងឈូកអេ

២៤. សហគមន៍ បឹងត្របែកភូមិបួន

២៥. សហគមន៍ ផ្លូវរថភ្លើង

២៦. សហគមន៍ ពង្រកជ័យល័ក្ខ
២៧. សហគមន៍ ពង្រសែនជ័យ
២៨. សហគមន៍ ព្រៃឈើត្រពាំងចាន់ (កំពង់ឆ្នាំង)
២៩. សហគមន៍ ព្រៃឈើភូមិត្នោត
៣០. សហគមន៍ ព្រៃឈើពេជ្រចង្វាល្អឆើត (កំពង់ឆ្នាំង)
៣១. សហគមន៍ ព្រៃឈើរតនៈរុក្ខា (ឧត្តរមានជ័យ)
៣២. សហគមន៍ ព្រៃឡង់ (ក្រចេះ)
៣៣. សហគមន៍ ព្រៃឡង់ (ព្រះវិហារ)
៣៤. សហគមន៍ ព្រៃឡង់ (ស្ទឹងត្រែង)
៣៥. សហគមន៍ ព្រៃកតាគង់បី
៣៦. សហគមន៍ ព្រៃកតាគង់ ហុកសិបម៉ែត្រ
៣៧. សហគមន៍ ព្រៃពាយ
៣៨. សហគមន៍ ភ្នំក្រោម (សៀមរាប)
៣៩. សហគមន៍ មានជ័យ
៤០. សហគមន៍រលួសជើងឯក
៤១. សហគមន៍ រស្មីសាមគ្គី
៤២. សហគមន៍ រស្មីសាមគ្គី (កំពង់ស្ពឺ)
៤៣. សហគមន៍ វាលតន្រ្ទី
៤៤. សហគមន៍ វាលស្បូវ
៤៥. សហគមន៍ ស្មសាន្ត
៤៦. សហគមន៍ សាមគ្គីចេកមាស
៤៧. សហគមន៍ សាមគ្គីរមាសហែក
៤៨. សហគមន៍ សាមគ្គីរុងរឿង
៤៩. សហគមន៍ ស្ត្រីក្លាហាន
៥០. សហគមន៍ ស្ត្រីឃ្លាំងសាំង
៥១. សហគមន៍ ស្ទឹងកំបុត
៥២. សហគមន៍ សែនរីករាយ
៥៣. សហគមន៍ ឡពាង
៥៤. សហគមន៍ អណ្តូងតាអៀង

៥៥. សហគមន៍ អមលាំង (កំពង់ស្ពឺ)

៥៦. សហគមន៍ ឬស្សីស្រស់

៥៧. សហព័ន្ធសហជីព កម្មករចំណីអាហារនិង សេវាកម្ម កម្ពុជា

៥៨. អង្គការតម្លាភាព

៥៩. អង្គការមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍

៦០. អង្គការសមាគមធាងត្នោត

៦១. អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស

៦២. អង្គការសមធម៌កម្ពុជា

**សម្រាប់ព័ត៌មានបន្ថែម៖**


១. លោក **អំ សំអាត** នាយកទទួលបន្ទុកកិច្ចការទូទៅនៃអង្គការលីកាដូ
លេខទំនាក់ទំនង៖ +៨៥៥ ១០ ៣២៧ ៧៧០

២. លោក **ស៊ាង មួយឡៃ** ប្រធានកម្មវិធីសិទ្ធិក្នុងទីក្រុង នៃអង្គការសមាគមធាងត្នោត
លេខទំនាក់ទំនង៖ +៨៥៥ ១៦ ៨៩៩ ៤៦៥